ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ
# ស្តីពី
# ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ
# ក្រសួងអប់រំ យុវជន និងកីឡា
# មុខងារគ្រោងថវិកា
# មូលនិធិដំណើរការសាលារៀនសាធារណៈ

( Advanced Excel )

នាយកដ្ឋានហិរញ្ញវត្ថុ
ឆ្នាំ ២០២៤

# មាតិកា

I. សេចក្តីផ្តើម ........ 1
II. ទិដ្ឋភាពទូទៅរបស់ប្រព័ន្ធគ្រោងថវិកា SOF ........ 1
III. ការបំពេញព័ត៌មានរបស់សាលារៀន ........ 1
IV. ការបំពេញសម្រង់មតិសាលារៀន ........ 2
១. អំពីអ្នកបំពេញព័ត៌មាន ........ 3
២. ព័ត៌មានទូទៅ ........ 3
៣. ប្រភពសិស្សដែលមករៀន ........ 4
៤. ព័ត៌មាននៃការសិក្សា ........ 5
៥. ព័ត៌មានលម្អិតអំពីដី ........ 5
៧. លទ្ធភាពនិងសំណូមពររបស់សហគមន៍ ........ 6
៨. ឈ្មោះគណៈកម្មការគ្រប់គ្រងសាលារៀន ........ 7
V. ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅ ........ 7
VI. ការគ្រោងផែនការយុទ្ធសាស្រ្តថវិកា ........ 9
VII. ផែនការសកម្មភាព ........ 10
VIII. គម្រោងចំណាយថវិកា SOF ដោយផ្សារភ្ជាប់ជាមួយស្តង់ដាសាលាគំរូ ........ 12
IX. គម្រោងចំណាយថវិកាប្រជុំបច្ចេកទេស ........ 14
X. ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ........ 15
XI. តារាងដែលត្រូវបោះពុម្ព ........ 16

## I. សេចក្តីផ្តើម

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដើម្បីកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាឱ្យស្របទៅនឹងកម្រិតស្តង់ដាអន្តរជាតិ ដែលមាន ដំណាក់កាល: (១) ការបង្កើនភាពជឿទុកចិត្តបាននៃថវិកា (២) គណនេយ្យភាពហិរញ្ញវត្ថុ (៣) ការផ្សារភ្ជាប់ ថវិកាទៅនឹងគោលនយោបាយ និង (៤) គណនេយ្យភាពសមិទ្ធកម្ម។

នាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡាបានខិតខំអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួង អប់រំ យុវជន និងកីឡា (EFMS) ក្នុងគោលបំណងធ្វើស្វ័យប្រវត្តិកម្មនូវដំណើរការការងារការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈដែលកំពុងធ្វើដោយដៃនាពេលបច្ចុប្បន្នឱ្យទៅជាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយដែល មានលក្ខណៈឌីជីថល ដោយគ្របដណ្តប់ទាំងការរៀបចំថវិកា ការអនុវត្តថវិកា កិច្ចបញ្ជិកាគណនេយ្យ របាយ ការណ៍ ការត្រួតពិនិត្យ និងការធ្វើសវនកម្ម លើប្រភពថវិការដ្ឋ និងថវិកាដៃគូអភិវឌ្ឍផងដែរ ហើយត្រូវបាន អភិវឌ្ឍដោយក្រុមការងារព័ត៌មានវិទ្យានៃនាយកដ្ឋានហិរញ្ញវត្ថុផ្ទាល់។

មុខងារគ្រប់គ្រងថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ (SOF) ជាមុខងារមួយនៅក្នុងប្រព័ន្ធ EFMS ដែលត្រូវបានរៀបចំឡើងដោយផ្អែកតាមគោលការណ៍ស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលា រៀនសាធារណៈ ដែលបានដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។ មុខងារនេះមានវិសាលភាពពី កម្រិតសាលារៀន ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត និងក្រសួងអប់រំ យុវជន និងកីឡា ដោយគ្របដណ្តប់លើគ្រប់ប្រភពថវិកាដែលបានប្រើប្រាស់នៅ តាមសាលារៀនសាធារណៈ។

សៀវភៅណែនាំស្តីពី "ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា មុខងារ គ្រោងថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ (Excel)" នេះត្រូវបានរៀបចំឡើង ក្នុងគោលបំណង ផ្តល់ការណែនាំដល់អ្នកប្រើប្រាស់អំពីរបៀបនៃការគ្រោងថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ (Excel) ប្រកបដោយភាពត្រឹមត្រូវ និងដើម្បីជំរុញឱ្យការបំពេញភារកិច្ចឱ្យបានកាន់តែប្រសើរ។

## II. ទិដ្ឋភាពទូទៅរបស់ប្រព័ន្ធគ្រោងថវិកា SOF

ការគ្រោងថវិកា SOF សម្រាប់ឆ្នាំ២០២៥ សាលារៀនសាធារណៈទាំងអស់ និងគ្រប់កម្រិតត្រូវគ្រោងដោយផ្សារភ្ជាប់គម្រោងថវិកាទៅនឹងស្តង់ដាសាលាគំរូ ផែនការយុទ្ធសាស្រ្តថវិកា និងផែនការប្រតិបត្តិប្រចាំឆ្នាំ។




## III. ការបំពេញព័ត៌មានរបស់សាលារៀន

**Sheet: School Information**

Sheet នេះសម្រាប់បំពេញព័ត៌មានផ្សេងៗរបស់សាលារៀន ដើម្បីគណនាពិតានថវិកាសម្រាប់គ្រោង។ ដើម្បីជៀសវាងមានទិន្នន័យចាស់ សូមធ្វើការសម្អាតដោយចុចប៊ូតុង "លុបទិន្នន័យចាស់"។

| សូមបំពេញព័ត៌មានរបស់សាលារៀនដូចខាងក្រោម | |
|---|---|
| ឆ្នាំថវិកា | ២០២៥ |
| រាជធានី ខេត្ត | |
| ក្រុង/ស្រុក/ខណ្ឌ | |
| ឃុំ/សង្កាត់ | |
| ឈ្មោះសាលា | |
| លេខកូដសាលា | |
| ប្រភេទសាលា | |
| សកម្មភាព | |
| តំបន់ | |
| ចំនួនសិស្ស | |
| ចំនួនសិស្សស្រី | |
| ចំណាយថេរ/ចំណាយគាំទ្រ (៛) | - |
| ចំណាយអថេរ/ចំណាយលើសិស្សម្នាក់ (៛) | - |
| ថវិកាបន្ថែម (៛/សាលា) | - |
| កញ្ចប់ថវិកាសរុប (៛) | - |

មុនពេលប្រើប្រាស់ សូមចុចប៊ូតុង "លុបទិន្នន័យចាស់" ខាងក្រោមជាមុនសិនដើម្បីប្រាកដថាមិនមានទិន្នន័យចាស់សល់ពីមុន។

លុបទិន្នន័យចាស់ | ចម្លងទិន្នន័យពីប្រព័ន្ធឆ្នាំចាស់

សូមបំពេញទិន្នន័យតាម Cell ដែលមានពណ៌សដូចខាងក្រោម៖

- ឆ្នាំថវិកា ៖ បំពេញឆ្នាំថវិកា (ស្វ័យប្រវត្តិ)
- រាជធានី ខេត្ត ៖ ជ្រើសរើសឈ្មោះរាជធានី ខេត្ត
- ក្រុង/ស្រុក/ខណ្ឌ ៖ ជ្រើសរើសឈ្មោះក្រុង/ស្រុក/ខណ្ឌ
- ឃុំ/សង្កាត់ ៖ ជ្រើសរើសឈ្មោះឃុំ/សង្កាត់
- ឈ្មោះសាលា ៖ ជ្រើសរើសឈ្មោះសាលារៀន
- ប្រភេទសាលា ៖ ជ្រើសរើសប្រភេទសាលារៀន
- បំពេញចំនួនសិស្ស

**ឧទាហរណ៍៖**

| សូមបំពេញព័ត៌មានរបស់សាលារៀនដូចខាងក្រោម | |
|---|---|
| ឆ្នាំថវិកា | ២០២៥ |
| រាជធានី ខេត្ត | ខេត្តកំពង់ធំ |
| ក្រុង/ស្រុក/ខណ្ឌ | ស្រុកសន្ទុក |
| ឃុំ/សង្កាត់ | តាំងក្រសាំង |
| ឈ្មោះសាលា | វិទ្យាល័យ តាំងក្រសាំង |
| លេខកូដសាលា | 06070807901 |
| ប្រភេទសាលា | វិទ្យាល័យ |
| សកម្មភាព | ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា |
| តំបន់ | តំបន់ធម្មតា |
| ចំនួនសិស្សទុតិយភូមិ | 345 |
| ចំនួនសិស្សស្រីទុតិយភូមិ | 200 |
| ចំណាយថេរ/ចំណាយគាំទ្រ (៛) | 6,200,000 |
| ចំណាយអថេរ/ចំណាយលើសិស្សម្នាក់ (៛) | 30,600 |
| ថវិកាបន្ថែម (៛/សាលា) | 2,500,000 |
| កញ្ចប់ថវិកាសរុប (៛) | **19,257,000** |
| តើមានអនុវិទ្យាល័យក្នុងវិទ្យាល័យដែរឬទេ? | មាន |
| ចំនួនសិស្សបឋមភូមិ | 200 |
| ចំនួនសិស្សស្រីបឋមភូមិ | 100 |
| កញ្ចប់សរុប | 6,120,000 |
| **កញ្ចប់រួមសរុប** | **25,377,000** |

មុនពេលប្រើប្រាស់ សូមចុចប៊ូតុង "លុបទិន្នន័យចាស់" ខាងក្រោមជាមុនសិនដើម្បីប្រាកដថាមិនមានទិន្នន័យចាស់សល់ពីមុន។

លុបទិន្នន័យចាស់ | ចម្លងទិន្នន័យពីប្រព័ន្ធឆ្នាំចាស់

## IV. ការបំពេញសម្រង់មតិសាលារៀន

### Sheet: សម្រង់ស្ថិតិសាលារៀន

Sheet នេះត្រូវបានរៀបចំឡើងសម្រាប់អ្នកប្រើប្រាស់បំពេញនូវព័ត៌មានទូទៅរបស់សាលារៀន ប្រភពសិស្ស ថ្នាក់រៀន ស្ថានភាពដី អគារ។ល។

ដើម្បីឱ្យការបំពេញព័ត៌មានដោយមិនមានបញ្ហា សូមលោក លោកស្រីកុំប្រើប្រាស់វិធីសាស្រ្តបញ្ចូលដោយ Copy (Ctrl+C), Paste (Ctrl+V) ឬ Cut (Ctrl+X)។ រាល់ទិន្នន័យជាលេខ ឬឆ្នាំ សូមបញ្ចូលជាលេខឡាតាំង (ជៀសវាងដាច់ខាតបញ្ចូលលេខជា Khmer Unicode)។

## ១. អំពីអ្នកបំពេញព័ត៌មាន

- ឈ្មោះ ៖ បំពេញឈ្មោះអ្នកបំពេញព័ត៌មាន
- តួនាទី ៖ បំពេញតួនាទីអ្នកបំពេញព័ត៌មាន
- ទូរស័ព្ទ ៖ បំពេញលេខទូរស័ព្ទ

**ឧទាហរណ៍៖**

| ១. អំពីអ្នកបំពេញព័ត៌មាន | | | | | | |
|---|---|---|---|---|---|---|
| | ឈ្មោះ | សុខ សាន្ត | តួនាទី | នាយក | ទូរស័ព្ទ | 012 123 456 |

**សូមបំពេញលេខកូដទីតាំងដែលនៅលើផែនទី**

**សូមបំពេញលេខកូដទីតាំងដែលនៅលើផែនទី ដោយបំពេញតម្លៃ X និង Y**

**ឧទាហរណ៍៖**

| | | | |
|---|---|---|---|
| លេខកូដទីតាំងលើផែនទី X: | 12.5705366 | Y: | 105.03799 |

## ២. ព័ត៌មានទូទៅ

**សម្រាប់បំពេញព័ត៌មាន ៖**

- ភូមិ ៖ សូមបំពេញតែឈ្មោះរបស់ភូមិ។ ឧ. "ភូមិត្បែង" សូមបំពេញ "ត្បែង"
- តើមានអគ្គិសនីប្រើប្រាស់ដែរ ឬទេ? ៖ សូមធ្វើការជ្រើសរើស មាន/មិនមាន អគ្គិសនីដែលផ្គត់ផ្គង់ដោយរដ្ឋ ឬក្រុមហ៊ុនឯកជន
- ទីតាំងសាលា ៖ សូមជ្រើសរើសទីតាំងរបស់សាលារៀន (ទីប្រជុំជន/ជនបទ/ដាច់ស្រយាល/ជាយដែន)
- តើសាលាស្ថិតក្នុងកម្រងអ្វី? ៖ ជាកម្រងសាលា
- តើសាលានេះស្ថិតក្នុងឧបសម្ព័ន្ធរបស់សាលាឈ្មោះអ្វី? ៖ ករណីសាលានេះមិនស្ថិតក្រោមឧបសម្ព័ន្ធសាលាណាមួយទេ សូមរក្សាទុកទទេ (មិនចាំបាច់បំពេញ)
- ថ្នាក់រៀនបច្ចុប្បន្នចាប់ពីថ្នាក់ ៖ សូមជ្រើសរើសកម្រិតថ្នាក់ទាបបំផុតដែលមាននៅក្នុងសាលារៀន (K1 = មត្តេយ្យថ្នាក់កម្រិតទាប, K2 = មត្តេយ្យថ្នាក់កម្រិតមធ្យម,K3 = មត្តេយ្យថ្នាក់កម្រិតខ្ពស់,G1= ថ្នាក់ទី១,G2= ថ្នាក់ទី២,….,G12=ថ្នាក់ទី១២)
- ថ្នាក់រៀនបច្ចុប្បន្នដល់ថ្នាក់ ៖ សូមជ្រើសរើសកម្រិតថ្នាក់ខ្ពស់បំផុតដែលមាននៅក្នុងសាលារៀន (K1 = មត្តេយ្យថ្នាក់កម្រិតទាប, K2 = មត្តេយ្យថ្នាក់កម្រិតមធ្យម,K3 = មត្តេយ្យថ្នាក់កម្រិតខ្ពស់ ,G1= ថ្នាក់ទី១,G2= ថ្នាក់ទី២,….,G12=ថ្នាក់ទី១២)
- ចំនួនវេន ៖ បំពេញចំនួនវេនដែលសាលាមានបង្រៀន
- ចំនួនគ្រូបង្រៀន ៖ បំពេញចំនួនគ្រូបង្រៀនសរុប (រាប់តែចំនួនគ្រូបង្រៀនសុទ្ធ)
- ចំនួនគ្រូជាប់កិច្ចសន្យា ៖ បំពេញចំនួនគ្រូកិច្ចសន្យាសរុប

- ចំនួនគ្រូមិនបង្រៀន ៖ បំពេញចំនួនគ្រូមិនបង្រៀនសរុប
- ចម្ងាយផ្លូវពីសាលាទៅទីរួមខេត្ត ៖ បំពេញចំនួនគីឡូម៉ែត្រ
- ចម្ងាយផ្លូវពីសាលាទៅទីរួមស្រុក ៖ បំពេញចំនួនគីឡូម៉ែត្រ។

ឧទាហរណ៍៖

| ២. ព័ត៌មានទូទៅ | |
|---|---|
| លេខកូដសាលា School ID | 06070807901 |
| ឈ្មោះសាលារៀនជាភាសាខ្មែរ | វិទ្យាល័យ តាំងក្រសាំង |
| ឈ្មោះសាលារៀនជាភាសាអង់គ្លេស | High School : Taingkrasaing |
| ប្រភេទសាលា | វិទ្យាល័យ |
| រាជធានី ខេត្ត | ខេត្តកំពង់ធំ |
| ក្រុង/ស្រុក/ខណ្ឌ | ស្រុកសន្ទុក |
| ឃុំ/សង្កាត់ | តាំងក្រសាំង |
| ភូមិ | ដីមាយ |
| តើមានអគ្គិសនីប្រើប្រាស់ដែរ ឬទេ ? | មាន |
| ទីតាំងសាលារៀន | ទីប្រជុំជន |
| តើសាលានេះស្ថិតក្នុងកម្រងអ្វី ? | កកោះ |
| តើសាលានេះស្ថិតក្នុងឧបសម្ព័ន្ធរបស់សាលាឈ្មោះអ្វី ? | |
| ថ្នាក់រៀនបច្ចុប្បន្នចាប់ពីថ្នាក់ | G7 |
| ថ្នាក់រៀនបច្ចុប្បន្នដល់ថ្នាក់ | G12 |
| ចំនួនសិស្សសរុប | 545 |
| សិស្សស្រី | 300 |
| ចំនួនវេន | 1 |
| ចំនួនគ្រូបង្រៀន | 36 |
| ចំនួនគ្រូជាប់កិច្ចសន្យា | - |
| ចំនួនគ្រូមិនបង្រៀន | 9 |
| ចម្ងាយផ្លូវពីសាលាទៅទីរួមខេត្ត ( គិតជាគីឡូម៉ែត្រ ) | 19.0 |
| ចម្ងាយផ្លូវពីសាលាទៅទីរួមស្រុក ( គិតជាគីឡូម៉ែត្រ ) | 10.0 |

## ៣. ប្រភពសិស្សដែលមករៀន

**សម្រាប់បំពេញព័ត៌មាន ៖**

- ឈ្មោះភូមិ/ឃុំ-សង្កាត់/ស្រុក-ខណ្ឌ ៖
  - សម្រាប់បឋមសិក្សាសូមបំពេញឈ្មោះរបស់ "ភូមិ"
  - សម្រាប់អនុវិទ្យាល័យសូមបំពេញឈ្មោះរបស់ "ឃុំ-សង្កាត់"
  - សម្រាប់វិទ្យាល័យសូមបំពេញឈ្មោះរបស់ "ស្រុក-ខណ្ឌ"
- ចំនួនសិស្ស ៖ បំពេញចំនួនសិស្សសរុប
- កុមារពីអាយុ ៤ ដល់ ១៨ឆ្នាំ ៖ បំពេញសិស្សសរុបដែលមានអាយុចាប់ពី ៤ ដល់ ១៨ឆ្នាំ
- ចម្ងាយផ្លូវពីភូមិ ទៅសាលា ៖ បំពេញចម្ងាយផ្លូវគិតជាគីឡូម៉ែត្រ
- ចំនួនគ្រួសារ ៖ បំពេញចំនួនគ្រួសារសរុប

ឧទាហរណ៍៖

**៣. ប្រភពសិស្សដែលមករៀន**

| ល.រ | បំពេញឈ្មោះភូមិសម្រាប់បឋម ឃុំ-សង្កាត់ សម្រាប់ អនុវិទ្យាល័យ ស្រុក-ខណ្ឌ សម្រាប់ វិទ្យាល័យ | ចំនួនសិស្សសរុប (នាក់) | ចំនួនសិស្សស្រី (នាក់) | ចំនួនកុមារពីអាយុ ៤ ដល់ ១៨ ឆ្នាំ (នាក់) | ចម្ងាយផ្លូវពីភូមិ ទៅសាលា (គិតជាគីឡូម៉ែត្រ) | ចំនួនគ្រួសារ |
|---|---|---|---|---|---|---|
| 1 | ស្រុកសន្ទុក | 827 | 430 | 443 | 6.0 | 36 |
| 2 | | | | | | |
| 3 | | | | | | |
| 4 | | | | | | |
| 5 | | | | | | |
| 6 | | | | | | |

# ៤. ព័ត៌មាននៃការសិក្សា

## សូមធ្វើការបំពេញព័ត៌មាន ៖

- ចំនួនបន្ទប់រៀន ៖ បំពេញចំនួនបន្ទប់រៀនដែលមានសរុបនៅក្នុងសាលារៀន
- ចំនួនថ្នាក់រៀន ៖ បំពេញចំនួនថ្នាក់រៀនសរុបដែលមាននៅក្នុងសាលារៀន។ ឧ. បន្ទប់មួយរៀន ២ ថ្នាក់
- ចំនួនវេន ៖ បំពេញចំនួនវេនដែលបង្រៀន។ ឧ. វេនព្រឹក វេនថ្ងៃ
- ចំនួនគ្រូសរុប ៖ បំពេញចំនួនគ្រូដែលបង្រៀនសរុប
- ចំនួនសិស្សស្រី ៖ បំពេញចំនួនសិស្សស្រីសរុបដែលមាននៅក្នុងសាលារៀន
- ថ្នាក់ទាបបំផុត ៖ ជ្រើសរើសកម្រិតថ្នាក់ទាបបំផុតដែលមាននៅក្នុងសាលារៀន
- ថ្នាក់ខ្ពស់បំផុត ៖ ជ្រើសរើសកម្រិតថ្នាក់ខ្ពស់បំផុតដែលមាននៅក្នុងសាលារៀន

ឧទាហរណ៍៖

- ឆ្នាំN-2 ត្រូវជាឆ្នាំ ២០២២
- ឆ្នាំN-1 ត្រូវជាឆ្នាំ ២០២៣
- ឆ្នាំN ដែលជាឆ្នាំបច្ចុប្បន្ន ត្រូវជាឆ្នាំ ២០២៤

**៤. ព័ត៌មាននៃការសិក្សា**

| ឆ្នាំសិក្សា N-2 | | ឆ្នាំសិក្សា N-1 | | ឆ្នាំសិក្សាបច្ចុប្បន្ន (N) | | |
|---|---|---|---|---|---|---|
| ចំនួនបន្ទប់រៀន | 22 | ចំនួនបន្ទប់រៀន | 22 | ចំនួនបន្ទប់រៀន | 22 | |
| ចំនួនថ្នាក់រៀន | 20 | ចំនួនថ្នាក់រៀន | 19 | ចំនួនថ្នាក់រៀន | 20 | |
| ចំនួនវេន | 1 | ចំនួនវេន | 1 | ចំនួនវេន | 1 | |
| ចំនួនគ្រូសរុប | 36 | ចំនួនគ្រូសរុប | 36 | ចំនួនគ្រូសរុប | 45 | |
| ចំនួនសិស្សសរុប | 818 | ចំនួនសិស្សសរុប | 783 | ចំនួនសិស្សសរុប | 800 | |
| ចំនួនសិស្សស្រី | 463 | ចំនួនសិស្សស្រី | 447 | ចំនួនសិស្សស្រី | 500 | |
| ថ្នាក់ទាបបំផុត | G7 | ថ្នាក់ទាបបំផុត | G7 | ថ្នាក់ទាបបំផុត | G7 | |
| ថ្នាក់ខ្ពស់បំផុត | G12 | ថ្នាក់ខ្ពស់បំផុត | G12 | ថ្នាក់ខ្ពស់បំផុត | G12 | |

# ៥. ព័ត៌មានលម្អិតអំពីដី

## សម្រាប់បំពេញព័ត៌មាន ៖

- បណ្តោយ ៖ សូមបញ្ចូលតែដីជាកម្មសិទ្ធិរបស់សាលារៀន។ បើទ្រង់ទ្រាយដីមិនមែនជាការេ ឬចតុកោណកែង ពុំចាំបាច់បំពេញប្រវែងបណ្តោយទេ ប៉ុន្តែសូមបំពេញក្រឡាផ្ទៃនៅផ្នែកខាងស្តាំ
- ទទឹង ៖ សូមបញ្ចូលតែដីជាកម្មសិទ្ធិរបស់សាលារៀន។ បើទ្រង់ទ្រាយដីមិនមែនជាការេ ឬចតុកោណកែង ពុំចាំបាច់បំពេញប្រវែងទទឹងទេ ប៉ុន្តែសូមបំពេញក្រឡាផ្ទៃនៅផ្នែកខាងស្តាំ
- ក្រឡាផ្ទៃ៖ បំពេញក្រឡាផ្ទៃសរុប ក្នុងករណីដែលមិនអាចគណនាបណ្តោយ និងទទឹង

- របង (បើមាន) ៖ បំពេញប្រវែងរបង គិតជាម៉ែត្រ
- ប្រភពទឹក ៖ សូមជ្រើសរើសប្រភពទឹក (ទឹកស្អាត ស្រះ អណ្តូង ផ្សេងៗ)
- ចំនួនបន្ទប់នៃបង្គន់ (បើមាន) ៖ បំពេញចំនួនបង្គន់សរុប
- នីវ៉ូទឹកលិចលើទីធ្លាសាលា ៖ គិតជាម៉ែត្រ
- នីវ៉ូទឹកលិចធៀបនឹងអគារ ៖ គិតជាម៉ែត្រ

**ឧទាហរណ៍៖**

| ៥. ពត៌មានលម្អិតអំពីដី | | | |
|---|---|---|---|
| បណ្តោយ (គិតជាម៉ែត្រ) | 180 | | |
| ទទឹង (គិតជាម៉ែត្រ) | 102 | ក្រឡាផ្ទៃ (គិតជាម៉ែត្រការ៉េ) | 18,360 |
| របង(បើមាន) (គិតជាម៉ែត្រ) | 600 | | |
| ប្រភពទឹក(បើមាន) | ទឹកស្អាត | | |
| ចំនួនបន្ទប់នៃបង្គន់(បើមាន) | 19 | | |
| នីវ៉ូទឹកលិចលើទីធ្លាសាលា (គិតជា | 0.0 | | |
| នីវ៉ូទឹកលិចធៀបនឹងអគារ (គិតជាម៉ែត្រ) | 0.0 | | |

## ៦. ស្ថានភាពអគារ

### សូមបំពេញព័ត៌មាន ៖

- ឆ្នាំសាងសង់ ៖ ជាឆ្នាំដែលបានសាងសង់អគារ
- សាងសង់ដោយ ៖ សូមជ្រើសរើសប្រភពថវិកាដែលបានសាងសង់អគារសាលារៀន
- ចំនួនបន្ទប់ ៖ ជាចំនួនបន្ទប់សរុបបានចែកចេញជា ២ ប្រភេទ គឺបន្ទប់រៀន និងបន្ទប់ការិយាល័យ
- កម្រាល ៖ បានចែកចេញជា ៤ ប្រភេទ គឺបេតុង ការ៉ូ ចាក់សាប ចាក់ដី ដែលត្រូវបំពេញជាអក្សរ G= ខូច 0-5%, SD= ខូច 6-25%, D= ខូច 26-50%, VD= ខូច 51-75%, BVD= ខូចលើស 75%
- ជញ្ជាំង ៖ សូមបំពេញប្រភេទ និងលក្ខណៈនៃជញ្ជាំង (លក្ខណៈត្រូវបំពេញជាអក្សរតំណាងដូចកម្រាលដែរ)
- ដំបូល ៖ សូមបំពេញប្រភេទ និងលក្ខណៈនៃដំបូល (លក្ខណៈត្រូវបំពេញជាអក្សរតំណាងដូចកម្រាលដែរ)

**ឧទាហរណ៍៖**

| ៦. ស្ថានភាពអគារ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ល.រ | ឆ្នាំសាងសង់ (ជាលេខឡាតាំង ៤ខ្ទង់) | ប្រភពមូលនិធិ | ចំនួនបន្ទប់ | | កម្រាល (សូមជ្រើសរើស) | | | | ជញ្ជាំង (សូមជ្រើសរើស) | | ដំបូល (សូមជ្រើសរើស) | | ចំនួនជាន់ | ឆ្នាំជួសជុលចុងក្រោយ | ស្ថានភាព |
| | | | រៀន | ការិយាល័យ | បេតុង | ការ៉ូ | ចាក់សាប | ចាក់ដី | ប្រភេទជញ្ជាំង | លក្ខណៈ | ប្រភេទដំបូល | លក្ខណៈ | | | |
| 1 | 1997 | រដ្ឋ | 9 | 1 | G | | | | ថ្ម | SD | ក្បឿង | G | 0 | | មធ្យម |
| 2 | 2008 | រដ្ឋ | 18 | 3 | | G | | | ថ្ម | G | ក្បឿង | G | 0 | | ល្អ |
| 3 | | | | | | | | | | | | | | | |
| 4 | | | | | | | | | | | | | | | |
| 5 | | | | | | | | | | | | | | | |
| 6 | | | | | | | | | | | | | | | |
| 7 | | | | | | | | | | | | | | | |

## ៧. លទ្ធភាពនិងសំណូមពររបស់សហគមន៍

### សម្រាប់បំពេញព័ត៌មាន ៖

- រៀបរាប់ពីតម្រូវការរបស់សាលា ៖ សូមបំពេញចំនួនតម្រូវការ
- សមត្ថភាព និងការចូលរួមរបស់សហគមន៍

- ការថែទាំនៅពេលអនាគត ៖ សូមជ្រើសរើស (បាទ/ចាស ឬ ទេ)

ឧទាហរណ៍៖

| ៧. លទ្ធភាពនិងសំណូមពររបស់សហគមន៍ | | | | |
|---|---|---|---|---|
| ល.រ | រៀបរាប់ពីតម្រូវការរបស់សាលា | | សមត្ថភាព និងការចូលរួមរបស់សហគមន៍ | ការថែទាំនៅពេលអនាគត |
| 1 | បន្ទប់រៀនដែលស្នើសុំសាងសង់ថ្មី | 20 | ជួយពិនិត្យមើលគុណភាពសំណង់ និងជាង | បាទ/ចាស |
| 2 | បន្ទប់រៀនដែលស្នើសុំជួសជុល | 10 | ជួយពិនិត្យមើលគុណភាពសំណង់ និងជាង | បាទ/ចាស |
| 3 | ចំនួនតុ កៅអីសិស្សដែលត្រូវស្នើសុំ | 70 | | បាទ/ចាស |
| 4 | ចំនួនបង្គន់ដែលត្រូវស្នើសុំ | 4 | | បាទ/ចាស |
| 5 | ផ្ទះគ្រូ | - | | បាទ/ចាស |

## ៨. ឈ្មោះគណៈកម្មការគ្រប់គ្រងសាលារៀន

**សម្រាប់បំពេញព័ត៌មាន ៖**

- ឈ្មោះ ៖ បំពេញឈ្មោះរបស់សមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន (គគស)
- តួនាទី ៖ សូមជ្រើសរើសតួនាទីរបស់សមាជិក គគស
- តួនាទីក្នុងសង្គម ៖ បំពេញតួនាទីជាក់ស្តែងនៅក្នុងសង្គម របស់សមាជិក គគស
- អាយុ ៖ បំពេញអាយុរបស់សមាជិក គគស

**ឧទាហរណ៍៖**

| ៨. ឈ្មោះគណៈកម្មការគ្រប់គ្រងសាលារៀន | | | | | |
|---|---|---|---|---|---|
| ល.រ | ឈ្មោះ | តួនាទីក្នុងកម្មការ (សូមជ្រើសរើស) | តួនាទីក្នុងសង្គម | អាយុ | |
| 1 | ចាន់ បុប្ផា | អនុប្រធាន | មេភូមិ | 56 | |
| 2 | រស់ បានយូរ | អនុប្រធាន | មេភូមិ | 59 | |
| 3 | កែវ ដារ៉ា | សមាជិក | សមាជិកភូមិ | 37 | |
| 4 | សុក សៅ | សមាជិក | ជំទប់ទី១ | 55 | |
| 5 | | | | | |
| 6 | | | | | |

# V. ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅ

Sheet: BSP_Indicator

Sheet នេះគឺសម្រាប់ដាក់ក្នុងសៀវភៅផែនការយុទ្ធសាស្ត្រថវិការបស់សាលារៀន។

**សូមបំពេញព័ត៌មាន ៖**

- ឆ្នាំមុន ៖ សម្រាប់បំពេញនៅលទ្ធផលដែលសម្រេចបាននៅឆ្នាំ n-1 អាចជាភាគរយ ឬជាលេខអាស្រ័យតាមសូចនាករ
- ឆ្នាំបច្ចុប្បន្ន ៖ សម្រាប់បំពេញគោលដៅឆ្នាំ n អាចជាភាគរយ ឬជាលេខអាស្រ័យតាមសូចនាករ
- ឆ្នាំគ្រោងថវិកា
  - គោលដៅ ៖ សម្រាប់បំពេញគោលដៅឆ្នាំ n+1 អាចជាភាគរយ ឬជាលេខអាស្រ័យតាមសូចនាករ
  - មូលហេតុនៃការផ្លាស់ប្តូរ ៖ សូមបំពេញអំពីមូលហេតុ
- ឆ្នាំគ្រោងថវិកា ៖ សម្រាប់បំពេញគោលដៅឆ្នាំ n+2 អាចជាភាគរយ ឬជាលេខអាស្រ័យតាមសូចនាករ
- ឆ្នាំគ្រោងថវិកា ៖ សម្រាប់បំពេញគោលដៅឆ្នាំ n+3 អាចជាភាគរយ ឬជាលេខអាស្រ័យតាមសូចនាករ

ឧទាហរណ៍៖

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| **តារាង ក៖ សូចនាករសមិទ្ធកម្ម និងគោលដៅ** | | | | | | | | | |
| | | ស្តង់ដា និងសូចនាករ | ឆ្នាំគ្រោងថវិកា ២០២៥ (រៀល) | គោលដៅសូចនាករសមិទ្ធកម្ម | | | | | |
| | | | | ឆ្នាំមុន* (២០២៣) | ឆ្នាំបច្ចុប្បន្ន (២០២៤) | ឆ្នាំគ្រោងថវិកា (២០២៥) | | ឆ្នាំគ្រោងថវិកា ២០២៦ | ឆ្នាំគ្រោងថវិកា ២០២៧ |
| | | | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្តូរ (ធៀបនឹងគោលដៅ ២០២៤) | | |
| **សរុប** | | | - | | | | | | |
| **កម្រិតវិទ្យាល័យ** | | | - | | | | | | |
| ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស | | | - | | | | | | |
| 4ST0101 | ការប្រមូលកុមារចូលរៀន | | - | | | | | | |
| | 4ST010101 | ភាគរយសិស្សថ្នាក់ទី១០ បានចូលរៀន | - | 94% | 96% | 98% | | 99% | 99% |
| 4ST0102 | កុមាររៀនបានគង់វង្សនៅក្នុងសាលារៀន | | - | | | | | | |
| | 4ST010201 | ភាគរយសិស្សបោះបង់ការសិក្សា | - | 10% | 8% | 5% | | 2% | 1% |
| 4ST0103 | លទ្ធផលនៃការសិក្សារបស់សិស្ស | | - | | | | | | |
| | 4ST010301 | ភាគរយសិស្សឡើងថ្នាក់ | - | 95% | 96% | 98% | | 99% | 99% |
| | | ភាគរយសិស្សទទួលបានលទ្ធផលសិក្សា និទ្ទេសA B C មុខវិជ្ជាភាសាខ្មែរ គ្រប់កម្រិតថ្នាក់ | | | | | | | |
| | | ភាគរយសិស្សទទួលបានលទ្ធផលសិក្សា និទ្ទេសA B C មុខវិជ្ជាគណិតវិទ្យា គ្រប់កម្រិតថ្នាក់ | | | | | | | |
| | | ភាគរយសិស្សទទួលបានលទ្ធផលសិក្សា និទ្ទេសA B C មុខវិជ្ជារូបវិទ្យា គ្រប់កម្រិតថ្នាក់ | | | | | | | |
| | | ភាគរយសិស្សទទួលបានលទ្ធផលសិក្សា និទ្ទេសA B C មុខវិជ្ជាគីមីវិទ្យា គ្រប់កម្រិតថ្នាក់ | | | | | | | |
| | | ភាគរយសិស្សទទួលបានលទ្ធផលសិក្សា និទ្ទេសA B C មុខវិជ្ជាជីវវិទ្យា គ្រប់កម្រិតថ្នាក់ | | | | | | | |

ប្រភពមូលនិធិ | School Information | សម្រង់ស្ថិតិសាលារៀន | OTHER_INFO | BSP_Indicator | BSP | BSP_Print | ACTIVITY | ACTIVITY_SUB_LEVEL | SOF | SOF_SUB_LEVEL | MEETING | TOTAL

**បញ្ជាក់៖** សាលារៀនត្រូវគិតគូរលើសូចនាករគ្រប់ប្រភពថវិកា និងគ្រប់កម្រិតសាលា។ សម្រាប់សាលារៀនដែលមានច្រើនកម្រិត សម្រាប់កម្រិតទី២សូមបំពេញសូចនាករនៅផ្នែកខាងក្រោមចាប់ពីជួរដេកទី ៥៦៤ តទៅ។

1. Plan-School 2025_New_Indicator.xlsb - Excel

D8 | fx | ស្តង់ដា និងសូចនាករ

| Row | D | E | F | G | H | I | J | K | L | M | N |
|---|---|---|---|---|---|---|---|---|---|---|---|
| 7 | **តារាង ក៖ សូចនាករសមិទ្ធកម្ម និងគោលដៅ** | | | | | | | | | | |
| 8–10 | | | ស្តង់ដា និងសូចនាករ | ឆ្នាំគ្រោងថវិកា ២០២៥ (រៀល) | គោលដៅសូចនាករសមិទ្ធកម្ម | | | | | | |
| | | | | | ឆ្នាំមុន* (២០២៣) | ឆ្នាំបច្ចុប្បន្ន (២០២៤) | ឆ្នាំគ្រោងថវិកា (២០២៥) | | ឆ្នាំគ្រោងថវិកា ២០២៦ | ឆ្នាំគ្រោងថវិកា ២០២៧ | |
| | | | | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្តូរ (ធៀបនឹងគោលដៅ ២០២៤) | | | |
| 564 | កម្រិតអនុវិទ្យាល័យ | | | - | | | | | | | OK |
| 565 | ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស | | | - | | | | | | | OK |
| 566 | 3ST0101 | ការប្រមូលកុមារចូលរៀន | | - | | | | | | | OK |
| 567 | | | ភាគរយសិស្សថ្នាក់ទី៧ បានចូលរៀន | | | | | | | | OK |
| 587 | 3ST0102 | កុមាររៀនបានគង់វង្សនៅក្នុងសាលារៀន | | - | | | | | | | OK |
| 588 | | | ភាគរយសិស្សបោះបង់ការសិក្សា | | | | | | | | OK |
| 608 | 3ST0103 | លទ្ធផលនៃការសិក្សារបស់សិស្ស | | - | | | | | | | OK |
| 609 | | 3ST010301 | ភាគរយសិស្សឡើងថ្នាក់ | - | 95% | 96% | 98% | | 99% | 99% | OK |
| 610 | | | ភាគរយសិស្សទទួលបានលទ្ធផលសិក្សា និទ្ទេសA B C មុខវិជ្ជាភាសាខ្មែរ គ្រប់កម្រិតថ្នាក់ | | | | | | | | OK |
| 611 | | | ភាគរយសិស្សទទួលបានលទ្ធផលសិក្សា និទ្ទេសA B C មុខវិជ្ជា គណិតវិទ្យាគ្រប់កម្រិតថ្នាក់ | | | | | | | | OK |
| 612 | | | ភាគរយសិស្សទទួលបានលទ្ធផលសិក្សា និទ្ទេសA B C មុខវិជ្ជារូបវិទ្យា គ្រប់កម្រិតថ្នាក់ | | | | | | | | OK |
| 613 | | | ភាគរយសិស្សទទួលបានលទ្ធផលសិក្សា និទ្ទេសA B C មុខវិជ្ជាគីមីវិទ្យា គ្រប់កម្រិតថ្នាក់ | | | | | | | | OK |
| 614 | | | ភាគរយសិស្សទទួលបានលទ្ធផលសិក្សា និទ្ទេសA B Cមុខវិជ្ជាជីវវិទ្យាគ្រប់កម្រិតថ្នាក់ | | | | | | | | OK |

ប្រភពមូលនិធិ | School Information | សម្រង់ស្ថិតិសាលារៀន | OTHER_INFO | BSP_Indicator | BSP | BSP_Print | ACTIVITY | ACTIVITY_SUB_LEVEL | SOF | SOF_SUB_LEVEL | MEETING | TOTAL BY EXP | SUBACCOU...

READY

## VI. ការគ្រោងផែនការយុទ្ធសាស្ត្រថវិកា

**Sheet: BSP**

Sheet នេះគឺសម្រាប់បញ្ចូលទិន្នន័យច្បាប់ហិរញ្ញវត្ថុរយៈពេល ៣ឆ្នាំ

- សម្រាប់បំពេញឥណទានទៅតាមសកម្មភាព ក្នុងករណីដែលមានថវិកាឆ្នាំ N និងតម្រូវការថវិកាតាមឆ្នាំនីមួយៗ ពីឆ្វេងទៅស្តាំ (ឧ. ពីឆ្នាំ២០២៥ ដល់ឆ្នាំ២០២៧) ៖
    - ថវិការដ្ឋ
    - ថវិកាដៃគូអភិវឌ្ឍន៍ (ស៊ុយអ៊ែត, គម្រោងពង្រឹងការអប់រំមធ្យមសិក្សា,.......)
    - ថវិកាសហគមន៍
    - ថវិកាផ្សេងៗ

**ឧទាហរណ៍៖**




បញ្ជាក់៖ Sheet នេះគឺមិនត្រូវបានយកទៅដាក់ក្នុងសៀវភៅផែនការយុទ្ធសាស្ត្រថវិកាទេ ដោយឡែកតារាងតម្រូវការថវិកាដែលត្រូវដាក់ក្នុងសៀវភៅផែនការយុទ្ធសាស្ត្រថវិកាគឺមានឈ្មោះ Sheet: BSP_Print




## VII. ផែនការសកម្មភាព

**Sheet: ACTIVITY**

Sheet នេះគឺសម្រាប់បំពេញលទ្ធផលគ្រោងទុក និងផែនការសកម្មភាពរបស់សាលារៀន។សកម្មភាពដែលត្រូវបំពេញគួរយកពីសៀវភៅស្តង់ដាសាលាគំរូ ព្រមទាំងត្រូវផ្សារភ្ជាប់ទៅនឹងសូចនាករដែលបានកំណត់នៅក្នុង Sheet: BSP_Indicator។ ការបំពេញផែនការសកម្មភាពគឺជាមូលដ្ឋានសម្រាប់បង្កើតផែនការប្រតិបត្តិប្រចាំឆ្នាំផងដែរ។

ទិន្នន័យត្រូវបំពេញមានដូចខាងក្រោម៖

1. លទ្ធផលគ្រោងទុក ៖ ជាចំនួនដែលបានគ្រោងទុកថានឹងបានអ្វី
2. សកម្មភាព ៖ ជាសកម្មភាពដែលបានធ្វើដើម្បីសម្រេចលទ្ធផលដែលបានគ្រោងទុក
3. លេខកូដសូចនាករ ៖ សូមជ្រើសរើសលេខកូដសូចនាករដែលយោងតាម sheet BSP_Indicator
4. ឯកតា ៖ សូមបំពេញឯកតានៃសកម្មភាព
5. លទ្ធផលតាមក្របខ័ណ្ឌពេលវេលា ៖ សូមបំពេញចំនួនទៅតាមត្រីមាសជាក់ស្តែង
6. អ្នកទទួលខុសត្រូវ ៖ សូមបំពេញឈ្មោះអ្នកទទួលខុសត្រូវ

**ឧទាហរណ៍៖**




ខ. ផែនការសកម្មភាព

| លេខកូដសកម្មភាព | លទ្ធផលគ្រោងទុក | សកម្មភាព | លេខកូដសូចនាករ | ឯកតា | លទ្ធផលតាមក្របខ័ណ្ឌពេលវេលា Q1 | Q2 | Q3 | Q4 | អ្នកទទួលខុសត្រូវ | |
|---|---|---|---|---|---|---|---|---|---|---|
| | កម្រិតវិទ្យាល័យ | | | | | | | | | OK |
| 4ACT01 | **ស្តង់ដារទី១៖ លទ្ធផលសិក្សារបស់សិស្ស** | | | | | | | | | OK |
| 4ACT0101 | ការប្រមូលកុមារចូលរៀន | | | | | | | | | OK |
| 4ACT010101 | សិស្សថ្នាក់ទី១០ បានចូលរៀន ចំនួន ៩៨% | រៀបចំទិន្នន័យសិក្សាតាមកម្រិតថ្នាក់ និងភូមិសិក្សា | 4ST010101 | ដង | | | | ១ | លោក តូច តន់ | OK |
| 4ACT0102 | កុមាររៀនបានគង់វង្សនៅក្នុងសាលារៀន | | | | | | | | | OK |
| 4ACT010201 | សិស្សបោះបង់ការសិក្សាច្រើនបំផុត ៥% | រៀបចំបញ្ជីឈ្មោះសិស្សលម្អិតតាមកម្រិតថ្នាក់ និងគ្រួសារ | 4ST010201 | ដង | | | | ១ | លោក តូច តន់ | OK |
| | | | | | | | | | | - |
| 4ACT0103 | លទ្ធផលនៃការសិក្សារបស់សិស្ស | | | | | | | | | OK |
| 4ACT010301 | សិស្សឡើងថ្នាក់ចំនួន ៩៨% | រៀបចំបញ្ជីឈ្មោះសិស្សតាមកម្រិតថ្នាក់ និងភូមិសិក្សា និ | 4ST010301 | ដង | | | | ១ | លោក តូច តន់ | OK |

បញ្ជាក់៖ ក្នុងករណីដែលសូចនាករមួយត្រូវសម្រេចដោយសកម្មភាពច្រើន នោះសកម្មភាពទាំងនោះត្រូវសរសេរក្នុងជួរដេកថ្មី ហើយជ្រើសរើសសូចនាករដូចគ្នា។

Sheet: ACTIVITY_SUB_LEVEL

សម្រាប់បំពេញសកម្មភាពដែលត្រូវធ្វើដើម្បីសម្រេចសូចនាកររបស់កម្រិតសិក្សាទី២ ចំពោះសាលាដែលមាន ២កម្រិត។ ឧទាហរណ៍ កម្រិតមត្តេយ្យសិក្សាដែលស្ថិតនៅក្នុងបឋមសិក្សា ឬកម្រិតអនុវិទ្យាល័យស្ថិតក្នុងវិទ្យាល័យជាដើម។

ទិន្នន័យត្រូវបំពេញមានដូចខាងក្រោម៖

1. លទ្ធផលគ្រោងទុក ៖ ជាចំនួនដែលបានគ្រោងទុកថានឹងបានអ្វី
2. សកម្មភាព ៖ ជាសកម្មភាពដែលបានធ្វើដើម្បីសម្រេចលទ្ធផលដែលបានគ្រោងទុក
3. លេខកូដសូចនាករ ៖ សូមជ្រើសរើសលេខកូដសូចនាករដែលយោងតាម sheet BSP_Indicator
4. ឯកតា ៖ សូមបំពេញឯកតានៃសកម្មភាព
5. លទ្ធផលតាមក្របខ័ណ្ឌពេលវេលា ៖ សូមបំពេញចំនួនទៅតាមត្រីមាសជាក់ស្តែង
6. អ្នកទទួលខុសត្រូវ ៖ សូមបំពេញឈ្មោះអ្នកទទួលខុសត្រូវ

ឧទាហរណ៍៖




បញ្ជាក់៖ ក្នុងករណីដែលសូចនាករមួយត្រូវសម្រេចដោយសកម្មភាពច្រើន នោះសកម្មភាពទាំងនោះត្រូវសរសេរក្នុងជួរដេកថ្មី ហើយជ្រើសរើសសូចនាករដូចគ្នា។

## VIII. គម្រោងចំណាយថវិកា SOF ដោយផ្សារភ្ជាប់ជាមួយស្តង់ដាសាលាគំរូ

**Sheet: SOF**

Sheet នេះគឺសម្រាប់គ្រោងថវិកាដោយលម្អិតតាមទំនិញ ឬសកម្មភាពដែលត្រូវធ្វើដោយផ្សារភ្ជាប់ទៅនឹងសកម្មភាពដែលបានកំណត់ក្នុងចំណុចទី V ខាងលើ។

- លេខកូដសកម្មភាព ៖ សូមជ្រើសរើសលេខកូដសកម្មភាព (សម្រាប់ផ្សារភ្ជាប់ទៅនឹងស្តង់ដាសាលាគំរូ)
- បរិយាយ ៖
  - ឈ្មោះសម្ភារៈ ឬសកម្មភាព(ឧ. ក្រដាសរ៉ាម)
  - ឯកតា ៖ សូមបំពេញប្រភេទឯកតា(ឧ. កេស)
  - តម្លៃឯកតា ៖ សូមបំពេញជាឥណទាន
- បំពេញបរិមាណសម្រាប់តម្រូវការលើកទី ១ ឬលើកទី ២




Sheet: SOF_SUB_LEVEL

Sheet នេះគឺសម្រាប់គ្រោងថវិកាដោយលម្អិតតាមទំនិញ ឬសកម្មភាពដែលត្រូវធ្វើដោយផ្សារភ្ជាប់ទៅនឹងសកម្មភាពដែលបានកំណត់ក្នុងចំណុចទី V ខាងលើ របស់កម្រិតសិក្សាទី២ ចំពោះសាលាដែលមាន ២កម្រិត។ ឧទាហរណ៍ កម្រិតមត្តេយ្យសិក្សាដែលស្ថិតនៅក្នុងបឋមសិក្សា ឬកម្រិតអនុវិទ្យាល័យស្ថិតក្នុងវិទ្យាល័យជាដើម។

ទិន្នន័យត្រូវបំពេញមានដូចខាងក្រោម៖

- លេខកូដសកម្មភាព ៖ សូមជ្រើសរើសលេខកូដសកម្មភាព (សម្រាប់ផ្សារភ្ជាប់ទៅនឹងស្តង់ដាសាលាគំរូ)
- បរិយាយ ៖
  - ឈ្មោះសម្ភារៈ ឬសកម្មភាព(ឧ. ក្រដាសរ៉ាម)
  - ឯកតា ៖ សូមបំពេញប្រភេទឯកតា(ឧ. កេស)
  - តម្លៃឯកតា ៖ សូមបំពេញជាតំណទាន
- បំពេញបរិមាណសម្រាប់តម្រូវការលើកទី ១ ឬលើកទី ២

**ឧទាហរណ៍៖**




ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការិយាល័យអប់រំ យុវជន និងកីឡា ស្រុកសន្ទុក
វិទ្យាល័យ តាំងក្រសាំង

មូលដ្ឋានគិតគម្រោងចំណាយមូលនិធិដំណើរការសាលារៀនសាធារណៈ សម្រាប់ឆ្នាំ ២០២៥

អនុវិទ្យាល័យក្នុងវិទ្យាល័យ ឯកតា៖ រៀល

| សកម្មភាព | អនុគណនី | បរិយាយ | | | លើកទី ១ ចំណាយប្រចាំ | | លើកទី ២ ចំណាយប្រចាំ | | សរុប | | | កញ្ចប់ថវិកាសរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឈ្មោះសម្ភារៈ ឬសកម្មភាព | ឯកតា | តំលៃឯកតា(រៀល) | បរិមាណ | ចំណាយ | បរិមាណ | ចំណាយ | ចំណាយប្រចាំ | ចំណាយមិនប្រចាំ | សរុប | ថវិកានៅសល់ត្រូវគ្រោង |
| **សរុបរួម** | | | | | | **7,694,000** | | **5,861,800** | **13,555,800** | - | **13,555,800** | |
| **គាំទ្រកិច្ចដំណើរការសាលារៀន** | | | | | | **1,800,000** | | **1,820,000** | **3,620,000** | - | **3,620,000** | |
| កិច្ចដំណើរការរដ្ឋបាល | **60028** | | | | | **1,680,000** | | **1,700,000** | **3,380,000** | - | **3,380,000** | |
| | 3ACT010101 | Printer EPSON L3210 | គ្រឿង | 600,000 | 1 | 600,000 | 1 | 600,000 | 1,200,000 | - | 1,200,000 | |
| | 3ACT010101 | Ink Botle EPSON | ដប | 25,000 | 4 | 100,000 | 4 | 100,000 | 200,000 | - | 200,000 | |
| | 3ACT010301 | Toner HP | ដុំ | 45,000 | 8 | 360,000 | 8 | 360,000 | 720,000 | - | 720,000 | |
| | 3ACT010101 | កាហ្វេ | កញ្ចប់ | 20,000 | 18 | 360,000 | 19 | 380,000 | 740,000 | - | 740,000 | |
| | | | | | | - | | - | - | - | - | |
| | 3ACT010301 | បេសកម្ម | នាក់ | 30,000 | 8 | 240,000 | 8 | 240,000 | 480,000 | - | 480,000 | |
| | | | | | | - | | - | - | - | - | |
| ការថែទាំ និងជួសជុលផ្សេងៗ | **61058** | | | | | **120,000** | | **120,000** | **240,000** | - | **240,000** | |
| | 3ACT010101 | ជួសជុលកុំព្យូទ័រ | គ្រឿង | 60,000 | 2 | 120,000 | 2 | 120,000 | 240,000 | - | 240,000 | |
| | | | | | | - | | - | - | - | - | |
| | | | | | | - | | - | - | - | - | |
| | | | | | | - | | - | - | - | - | |
| | | | | | | - | | - | - | - | - | |
| | | | | | | - | | - | - | - | - | |
| | | | | | | - | | - | - | - | - | |
| **កែលម្អគុណភាពបង្រៀន និងរៀន** | | | | | | **5,894,000** | | **4,041,800** | **9,935,800** | - | **9,935,800** | |

# IX. គម្រោងចំណាយថវិកាប្រជុំបច្ចេកទេស

## Sheet: MEETING

Sheet នេះគឺសម្រាប់គ្រោងថវិកាប្រជុំបច្ចេកទេសសម្រាប់សាលារៀន។

**សូមធ្វើការបំពេញព័ត៌មានដូចខាងក្រោម ៖**

- ប្រធានបទប្រជុំ ៖ សូមបញ្ជាក់ពីប្រធានបទ ឬគោលបំណងនៃការប្រជុំ
- ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធ ៖ សូមបំពេញចំនួនសមាជិកដែលត្រូវចូលរួមប្រជុំ

**ឧទាហរណ៍៖**

**មូលដ្ឋានគិតគម្រោងចំណាយថវិកាប្រជុំ សម្រាប់ឆ្នាំ ២០២៥**

ឯកតា៖ រៀល

| បរិយាយ | ប្រធានបទប្រជុំ | ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធ | ឧបត្ថម្ភ | សរុប |
|---|---|---|---|---|
| **សរុប** (61103) | | | | **1,260,000** |
| **មធ្យមសិក្សាចំណេះទូទៅ** | | | | **1,260,000** |
| **មូលដ្ឋានគិតគម្រោងថវិកាប្រជុំបច្ចេកទេសប្រចាំខែ** | | **252** | | **1,260,000** |
| ពេលទី១ | ធ្វើវិញ្ញាសាប្រឡងប្រចាំខែ | 36 | 5,000 | 180,000 |
| ពេលទី២ | ធ្វើវិញ្ញាសាប្រឡងប្រចាំឆមាសទី១ | 36 | 5,000 | 180,000 |
| ពេលទី៣ | ប្រជុំបូកសរុបលទ្ធផលឆមាសទី១ | 36 | 5,000 | 180,000 |
| ពេលទី៤ | ប្រជុំធ្វើវិញ្ញាសាប្រឡងប្រចាំខែ | 36 | 5,000 | 180,000 |
| ពេលទី៥ | ប្រជុំធ្វើវិញ្ញាសាប្រឡងប្រចាំខែ | 36 | 5,000 | 180,000 |
| ពេលទី៦ | ប្រជុំបូកសរុបលទ្ធផលឆមាសទី២ | 36 | 5,000 | 180,000 |
| ពេលទី៧ | ប្រជុំធ្វើវិញ្ញាសាប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | 36 | 5,000 | 180,000 |

# X. ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ

**Sheet: AOP**

Sheet នេះគឺសម្រាប់បញ្ចូលនូវឥណទានថវិកាដែលបានសម្រេចចុងក្រោយគ្រប់ប្រភពថវិកា។ ដោយឡែកសម្រាប់ថវិការដ្ឋ គឺត្រូវបានបង្ហាញដោយស្វ័យប្រវត្តិពីទីតាំងគ្រោងថវិកាប្រចាំឆ្នាំ។ ដូច្នេះ សូមបំពេញថវិកាសម្រាប់ប្រភពថវិកាក្រៅពីថវិការដ្ឋ។ Sheet នេះគឺមិនតម្រូវឱ្យបោះពុម្ពសម្រាប់ភ្ជាប់ជាមួយសៀវភៅផែនការប្រតិបត្តិប្រចាំឆ្នាំទេ រីឯ Sheet សម្រាប់ភ្ជាប់ជាមួយសៀវភៅផែនការប្រតិបត្តិប្រចាំឆ្នាំគឺមានឈ្មោះ AOP_Print ដែលនៅខាងស្តាំជាប់គ្នា។

**ឧទាហរណ៍៖**




លទ្ធផលផែនការប្រតិបត្តិប្រចាំឆ្នាំ

| Row | លេខកូដសកម្មភាព | លេខកូដសូចនាករ | លទ្ធផលគ្រោងទុក | សកម្មភាព | ឯកតា | Q1 | Q2 | Q3 | Q4 | អ្នកទទួលខុសត្រូវ | ថវិកាសរុប | 10101 ថវិការដ្ឋ (SOF) | 10101 ថវិការដ្ឋ (ក្រៅពី SOF) | 20302 គម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USESDP II) | 20401 មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍន៍សមត្ថភាពវិស័យអប់រំ (CDPF) | 20402 UNICEF | 20403 School Block Grant | 20404 VVOB ប្រចាំប្រទេសកម្ពុជា |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 4 | | | សរុប | | | | | | | | 9,141,400 | 9,141,400 | 500,000 | - | - | - | - | - |
| 5 | កម្រិតវិទ្យាល័យ | | | | | | | | | | 5,561,400 | 5,561,400 | 500,000 | - | - | - | - | - |
| 6 | 4ACT01 | | ស្តង់ដារទី១៖ លទ្ធផលសិក្សារបស់សិស្ស | | | | | | | | 5,561,400 | 5,561,400 | 500,000 | - | - | - | - | - |
| 7 | 4ACT0101 | | ការប្រមូលកុមារចូលរៀន | | | | | | | | 4,465,000 | 4,465,000 | - | - | - | - | - | - |
| 8 | 4ACT010101 | 4ST010101 | សិស្សថ្នាក់ទី១០ បានចូលរៀន ចំនួន ៩៨% | រៀបចំទិន្នន័យសិក្សាតាមកម្រិតថ្នាក់ និងភូមិសិក្សា | ដង | | | | 1 | លោក គួច គន់ | 4,465,000 | 4,465,000 | | | | | | |
| 28 | 4ACT0102 | | កុមាររៀនបានគង់វង្សនៅក្នុងសាលារៀន | | | | | | | | 956,400 | 456,400 | 500,000 | - | - | - | - | - |
| 29 | 4ACT010201 | 4ST010201 | សិស្សបោះបង់ការសិក្សាច្រើនបំផុត ៥% | រៀបចំបញ្ជីឈ្មោះសិស្សលម្អិតតាមកម្រិតថ្នាក់ និងគ្រួសារ | ដង | | | | 1 | លោក គួច គន់ | 956,400 | 456,400 | 500,000 | | | | | |
| 49 | 4ACT0103 | | លទ្ធផលនៃការសិក្សារបស់សិស្ស | | | | | | | | 640,000 | 640,000 | - | - | - | - | - | - |
| 50 | 4ACT010301 | 4ST010301 | សិស្សឡើងថ្នាក់ចំនួន ៩៨% | រៀបចំបញ្ជីឈ្មោះសិស្សតាមកម្រិតថ្នាក់ និងភូមិសិក្សា និងពិន្ទុប្រចាំឆ្នាំ | ដង | | | | 1 | លោក គួច គន់ | 640,000 | 640,000 | | | | | | |
| 70 | 4ACT0104 | | ស្ថានភាពអាហារូបត្ថម្ភរបស់សិស្ស | | | | | | | | - | - | - | - | - | - | - | - |
| 91 | 4ACT0105 | | សីលធម៌ និងឥរិយាបថរបស់សិស្ស | | | | | | | | - | - | - | - | - | - | - | - |
| 112 | 4ACT02 | | ស្តង់ដារទី២ ៖ ការបង្រៀន និងរៀន | | | | | | | | - | - | - | - | - | - | - | - |
| 113 | 4ACT0201 | | ការអនុវត្តវិធីសាស្ត្របង្រៀនថ្មី | | | | | | | | - | - | - | - | - | - | - | - |
| 134 | 4ACT0202 | | ការអនុវត្តកម្មវិធីសិក្សានិងការរៀបចំផែនការបង្រៀន | | | | | | | | - | - | - | - | - | - | - | - |
| 155 | 4ACT0203 | | សម្ភារៈរៀន និងបង្រៀន | | | | | | | | - | - | - | - | - | - | - | - |
| 176 | 4ACT0204 | | ការជួយគាំទ្រសិស្ស | | | | | | | | - | - | - | - | - | - | - | - |
| 197 | 4ACT0205 | | ដំណើរការបណ្ណាល័យ | | | | | | | | - | - | - | - | - | - | - | - |
| 218 | 4ACT0206 | | សាលារៀនបានធ្វើអធិការកិច្ចផ្ទៃក្នុង ត្រឹមត្រូវតាមផែនការកំណត់ | | | | | | | | - | - | - | - | - | - | - | - |
| 239 | 4ACT0207 | | ការប្រជុំបច្ចេកទេស | | | | | | | | - | - | - | - | - | - | - | - |
| 260 | 4ACT0208 | | ការអនុវត្តកម្មវិធីសិក្សាក្រៅម៉ោងសិក្សា | | | | | | | | - | - | - | - | - | - | - | - |
| 281 | 4ACT0209 | | ការអនុវត្តការអប់រំសីលធម៌ ចរិយាធម៌ | | | | | | | | - | - | - | - | - | - | - | - |
| 302 | 4ACT03 | | ស្តង់ដារទី៣ ៖ ការចូលរួមរបស់សហគមន៍ | | | | | | | | - | - | - | - | - | - | - | - |
| 303 | 4ACT0301 | | ការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន | | | | | | | | - | - | - | - | - | - | - | - |
| 324 | 4ACT0302 | | ការចូលរួមរបស់សហគមន៍ | | | | | | | | - | - | - | - | - | - | - | - |
| 345 | 4ACT0303 | | ការគាំទ្ររបស់សហគមន៍ | | | | | | | | - | - | - | - | - | - | - | - |
| 366 | 4ACT04 | | [illegible] | | | | | | | | | | | | | | | |



**Sheet: AOP_Print**




## XI. តារាងដែលត្រូវបោះពុម្ព

សម្រាប់តារាងដែលត្រូវបោះពុម្ពចំពោះផែនការរបស់សាលារៀនមានដូចខាងក្រោម៖

| ល.រ | ឈ្មោះ Sheet | គោលបំណង | ផ្សេង |
|---|---|---|---|
| ១ | Table 1.1 | គំរូ ១.១. ផែនការថវិកាសម្រាប់មូលនិធិដំណើរការសាលារៀន សាធារណៈឆ្នាំ ២០២៥ | |
| ២ | BSP_Indicator | តារាង ក៖ សូចនាករសមិទ្ធកម្ម និងគោលដៅ សម្រាប់ដាក់ក្នុងសៀវភៅផែនការយុទ្ធសាស្ត្រថវិកា | |
| ៣ | BSP_Print | ផែនការយុទ្ធសាស្ត្រថវិកា សម្រាប់ដាក់ក្នុងសៀវភៅផែនការយុទ្ធសាស្ត្រថវិកា | |
| ៤ | AOP_Print | សម្រាប់ដាក់ក្នុងសៀវភៅផែនការប្រតិបត្តិប្រចាំឆ្នាំ | |